ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីព្យាបាលជាសះស្បើយ ០៥នាក់
# និងករណីវិជ្ជមានកូវីដ-១៩ ថ្មី ០២នាក់ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

– អ្នកព្យាបាលជាសះស្បើយ សរុបចំនួនកើនដល់ ៦៣នាក់ (ស្មើនឹង ៥៣,៨៥% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១០នាក់ (ក្នុងនេះមានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ០៩នាក់ បុរសជនជាតិម៉ាឡេស៊ី ០៧នាក់ បុរសជនជាតិខ្មែរ ២៨នាក់ និងស្ត្រីជនជាតិខ្មែរ ០៤នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។

– អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន ៥៤នាក់ (ស្ត្រី ១៩នាក់ និងបុរស ៣៥នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

– អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១១៧នាក់ (ស្ត្រី ៣៤នាក់ និងបុរស ៨៣នាក់)។

**២. ករណីជាសះស្បើយ៖** មាន ០៥នាក់

- បុរសជនជាតិបារាំង ០២នាក់៖ បុរសអាយុ ៦៣ឆ្នាំ និងបុរសអាយុ ៦៧ឆ្នាំ ជាអ្នកទេសចរបារាំង បានសម្រាកព្យាបាលនៅសណ្ឋាគារក្នុងក្រុងព្រះសីហនុ បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក។ បុរសទាំងពីរនាក់នេះ ត្រូវបានដាក់ឲ្យនៅបន្ទប់ដាច់ដោយឡែកក្នុងសណ្ឋាគារក្នុងក្រុងព្រះសីហនុ ដើម្បីរង់ចាំជើងហោះហើរវិលត្រឡប់ទៅប្រទេសបារាំងវិញ។
- បុរសជនជាតិខ្មែរអាយុ ៣៦ឆ្នាំ នៅរាជធានីភ្នំពេញ ជាអ្នកដំណើរវិលត្រឡប់មកពីប្រទេសជប៉ុន បានសម្រាកព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ហើយត្រូវបានអនុញ្ញាតឲ្យចាកចេញពីមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៣៧ឆ្នាំ នៅរាជធានីភ្នំពេញ ជាអ្នកដំណើរវិលត្រឡប់មកពីប្រទេសជប៉ុន បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាត

ឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ។

- បុរសជនជាតិខ្មែរ អាយុ ២៨ឆ្នាំ នៅរាជធានីភ្នំពេញ (ជាអ្នករកស៊ីមានមិត្តភ័ក្រ្តចេញចូលនៅច្រកប៉ោយប៉ែតច្រើន) បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ។

**៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** ០២នាក់ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

- ស្ត្រីជនជាតិខ្មែរអាយុ ៥៥ឆ្នាំ ជាភរិយាបុរសអាយុ ៥៧ឆ្នាំខាងក្រោម មានលទ្ធផលតេស្តវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរអាយុ ៥៧ឆ្នាំ ត្រូវជាស្វាមីស្ត្រីអាយុ ៥៥ឆ្នាំខាងលើ រស់នៅសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ រកឃើញវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ។ បុរសរូបនេះ ជាមិត្តភ័ក្រ្តបុរសជនជាតិចិនចូលមកកម្ពុជានៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ (ជាអ្នកឧស្សាហ៍ធ្វើដំណើរឡើងចុះ និងក្រោយពីបានចាកចេញពីកម្ពុជានៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ ក៏បានរកឃើញមានវីរុសកូវីដ-១៩ ដោយអាជ្ញាធរសុខាភិបាលនៅប្រទេសចិន)។ ជនជាតិចិនរូបនេះ ជាមិត្តប្រុសរបស់ស្ត្រីជនជាតិវៀតណាមរកឃើញមានវីរុសកូវីដ-១៩ ដែលវត្ថុសំណាករបស់គាត់បានយកដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហើយបច្ចុប្បន្ននេះ បានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញវិញ ក្រោយពីបានចេញសេចក្តីជូនព័ត៌មាននាព្រឹកថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ រួចហើយ។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ ១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១១៧ ករណី




*សំគាល់៖ អ្នកជំងឺពីខេត្តកំពង់ចាម ចំនួន ០៤នាក់ បានមកព្យាបាលនៅមន្ទីរពេទ្យមួយក្នុងរាជធានីភ្នំពេញ*
*សូមកែតំរូវឈ្មោះខេត្តបាត់ដំបង និងព្រះវិហារ ដោយមានកំហុសបច្ចេកទេសកុំព្យូទ័រ*

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១១៧ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

សំគាល់៖ អ្នកជំងឺពីខេត្តកំពង់ចាម ចំនួន ០៤នាក់ បានមកព្យាបាលនៅមន្ទីរពេទ្យមួយក្នុងរាជធានីភ្នំពេញ